# San Diego Unified School District

EUGENE BRUCKER EDUCATION CENTER
4100 Normal Street, San Diego, CA 92103-2682
(619) 725-5506

**Terry B. Grier, Ed.D.**
**អគ្គស្នងការក្រសួងអប់រំ**

ខែ ធ្នូ ឆ្នាំ ២០០៨

មាតាបិតានិងអ្នកអាណាព្យាបាលសិស្សជាទីរាប់អាន:

រដូវថ្ងៃ បុណ្យ ជិតធ្លាក់មកដល់ ដូច្នេះខ្ញុំឆ្លៀតយកឱកាសនេះសូមថ្លែងអំគុណដល់លោកអ្នកដែលជាមាតាបិតាសិស្សបានធ្វើការខិតខំយ៉ាងសំខាន់ក្នុងការគាំទ្រសិស្សរបស់យើងធ្វើការសិក្សានៅតាមសាលារៀន។ ជាពិសេស ខ្ញុំមានសេចក្តីរីករាយដល់គ្រួសារសិស្សនៅតាមសាលារៀនទាំងអស់ ព្រមទាំងប្រជាជនរស់នៅក្នុងទីក្រុង San Diego បានគាំទ្របោះឆ្នោតអោយច្បាប់ " S " បានជាប់ ៦៨ភាគរយ កាលពីថ្ងៃទី ៤ ខែ វិច្ឆិកា កន្លងទៅនេះ។ ការបោះឆ្នោតនេះអាចអនុញ្ញាតិអោយក្រសួងអប់រំប្រចាំក្រុងរបស់យើងទទួលថវិការចំនួន ២.៥កោដិដុល្លារ សំរាប់ជុសជួល, កែឆ្នៃសាលារៀនចំនួន ១៨០សាលាអោយបានល្អប្រសើរដើម្បីផ្តល់សន្តិសុខសិស្ស និងបរិយាកាសដល់សិស្សធ្វើការសិក្សាអោយបានយ៉ាងល្អប្រសើរ។

ការសិក្សារបស់សិស្សនារដូវស្លឹកឈើមានការលូតលាស់ល្អ។ សិស្សានុសិស្ស និងលោកគ្រូ-អ្នកគ្រូរបស់យើងទាំងអស់បានធ្វើការយ៉ាងសកម្មដែលអាចទទួលលទ្ធផលបានយ៉ាងប្រសើរ ហើយក្រសួងអប់រំប្រចាំក្រុងរបស់យើងប្រឈរមុខតទល់នឹងការខ្វះខាតថវិការពីរដ្ឋ។ ថ្មីៗនេះ លោក Schwarzenegger ដែលជាចៅហ្វាយខែត្របានស្នើសុំអោយមានការកាត់បន្ថយថវិការចំនួន ២.៥កោដិដុល្លារ ថែមទៀតទៅលើក្រសួងផ្នែកអប់រំនាពាក់កណ្តាលឆ្នាំនេះ។ យើងនឹងធ្វើការយ៉ាងជិតស្និតជាមួយគណះកម្មការក្រសួងអប់រំប្រចាំក្រុងរបស់យើងដើម្បីធ្វើការពិនិត្យកិច្ចការកម្មវិធីអប់រំសំខាន់ៗ ព្រមទាំងរក្សាការកាត់បន្ថយការអប់រំបង្រៀនសិស្សនៅតាមថ្នាក់រៀន។ ខ្ញុំនឹងព្យាយាមអោយបានជាក់លាស់ថា នាមខ្ញុំជាអគ្គស្នងការអប់រំប្រចាំទីក្រុង San Diego ខ្ញុំនឹងគិតយកកិច្ចការនេះជាធំដើម្បីរក្សាសំឡេងអោយគេទទួលស្គាល់នៅរដ្ឋធានី Sacramento ក្នុងការគាំទ្រការកាត់បន្ថយថវិការរបស់សាលារៀនយើង។

ដើម្បីអនុលោកតាមគោលការច្បាប់របស់យើង យើងនឹងត្រូវការរក្សារួបរួមគ្នាអោយបានរឹងមាំជាមួយលោកគ្រូ-អ្នកគ្រូ, មាតាបិតាសិស្ស ព្រមទាំងសមាជិកសហគមន៍របស់យើងដើម្បីចែកចាយពត៌មានគ្នាទៅវិញទៅមកក្នុងផលប្រយោជន៍ការសិក្សារបស់សិស្សយើងទាំងអស់គ្នា។ នាសប្តាហ៍ខាងមុខនេះ យើងនឹងខិតខំធ្វើការ ហើយនឹងផ្តល់ពត៌មានជូនដល់លោកអ្នកអោយបានជ្រាបអំពី ការកាត់បន្ថយថវិការដល់ក្រសួងអប់រំរបស់យើង ហើយមាតាបិតាមួយចំនួនមានគោលការមកចូលរួមដើម្បីជួយផ្តល់ជាយោបល់-មិតិ។ សូមធ្វើការតាមដានពិនិត្យមើលពត៌មានតាមប្រព័ន website: www.sandi.net របស់ក្រសួងអប់រំស្តីអំពី ការសម្រេចថ្មីៗទៅលើថវិការសាលារៀន។

នារដូវបុណ្យឈប់សម្រាកនេះ ខ្ញុំសង្ឃឹមថា លោកអ្នកនឹងឆ្លៀតយកឱកាសនេះពិគ្រោះជាមួយកូនចៅអំពី អំណោយអប់រំដ៏សំខាន់សំរាប់អនាគត។ ខ្ញុំសូមអោយលោកអ្នកចំណាយពេលវេលាថ្លែង " អំណរគុណ " ដល់លោកគ្រូ-អ្នកគ្រូ នឹងបុគ្គលិកអប់រំទូទៅដែលបានជួយដល់កូនលោកអ្នកធ្វើការសិក្សា។ ពាក្យ ពីរម៉ាត់នេះគឺជាអំណោយមួយដ៏មានតម្លៃជាទីបំផុត។

សូមអរគុណលោកអ្នកជាថ្មីម្តងទៀតដែលបានជឿទុកចិត្តកូនមកចូលរៀននៅតាមសាលារៀនរបស់យើង។ សូមអោយលោកអ្នកមានសេចក្តីរីករាយ និងមានសុខភាពល្អនារដូវបុណ្យឈប់សម្រាកនេះ

ដោយក្តីរាក់ទាក់បំផុត,

Terry B. Grier, Ed.D.
អគ្គស្នងការអប់រំ